**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ ១៨៣.ស.ជ.អ

ភ្នំពេញ, ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់នាឡិកាទឹកមេកានិក-ខ្នាតតូច

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់នាឡិកាទឹកមេកានិក-ខ្នាតតូច។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ក្នុងមួយច្បាប់តម្លៃ ៦០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃគឺ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ១៤:៥០នាទី។

កាលបរិច្ឆេទបើកសំណើដេញថ្លៃគឺ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ១៤:៥០នាទី នៅអង្គភាពលទ្ធកម្ម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ(ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>ចម្លងជូន៖</u>
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ